ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ..... ក.ប/ប្រ.ក

ប្រកាស
ស្តីពី
បែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ កម្មករនិយោជិត និងការបង់ភាគទានក្នុងបេឡាជាតិសន្តិសុខសង្គម

រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ២០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៣៦ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ:(០២៣)៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- បានឃើញអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីរបបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

ប្រការ១ .-

ប្រកាសនេះ កំណត់អំពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ កម្មករនិយោជិត និងការបង់ភាគទានក្នុងបេឡាជាតិសន្តិសុខសង្គម (**ប.ស.ស.**) សំដៅធានាប្រសិទ្ធភាពក្នុងការអនុវត្តរបបសន្តិសុខសង្គម។

ប្រការ២ .-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះនិយោជក និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

ប្រការ៣ .-

និយោជកត្រូវចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ របស់ខ្លួនក្នុង **ប.ស.ស.** ក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបើកដំណើរការអាជីវកម្ម ឬការប្រើប្រាស់កម្មករនិយោជិត។

ការស្នើសុំចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ ត្រូវធ្វើឡើងតាមនីតិវិធីដូចខាងក្រោម៖

១-ចំពោះសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលបានចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមរយៈគេហទំព័រ https://registrationservices.gov.kh ត្រូវបានចុះបញ្ជីក្នុង **ប.ស.ស.** ដោយស្វ័យប្រវត្តិ។

២-ចំពោះសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលកំពុងដំណើរការអាជីវកម្ម និងមិនទាន់ចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ ក្នុង **ប.ស.ស.** និយោជកត្រូវចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ របស់ខ្លួនតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន **ប.ស.ស.** តាមរយៈគេហទំព័រ https://enterprise.nssf.gov.kh ឬកម្មវិធីទូរសព្ទដៃ NSSF Enterprise App ឬមកស្នាក់ការ **ប.ស.ស.** ដោយផ្ទាល់។

៣-ចំពោះម្ចាស់ផ្ទះដែលមានប្រើអ្នកបម្រើក្នុងផ្ទះ ត្រូវចុះបញ្ជីក្នុង **ប.ស.ស.** តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន **ប.ស.ស.** តាមរយៈគេហទំព័រ https://enterprise.nssf.gov.kh ឬតាមរយៈកម្មវិធីទូរសព្ទដៃ NSSF Enterprise App ឬមកស្នាក់ការ **ប.ស.ស.** ដោយផ្ទាល់។

ចំពោះការចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ ក្នុង **ប.ស.ស.** ត្រូវបំពេញទម្រង់ "ចុះបញ្ជីសហគ្រាស" (ហៅកាត់ថា **ទម្រង់ ១.០១**) ដែលមានចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ និងភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

ក- សម្រាប់សហគ្រាស ក្រុមហ៊ុន រោងចក្រ

- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ឬលិខិតដែលមានតម្លៃស្មើ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល ឬលិខិតឆ្លងដែន។

ខ- សម្រាប់ម្ចាស់ផ្ទះ

- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតបញ្ជាក់អត្តសញ្ញាណបុគ្គល ឬលិខិតឆ្លងដែន។

ក្នុងករណីដែលសហគ្រាស ក្រុមហ៊ុន រោងចក្រ មានសាខាមួយ ឬច្រើន និយោជកត្រូវចុះបញ្ជីសាខារបស់ខ្លួនក្នុង **ប.ស.ស.** ដោយផ្ទាល់ ឬតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន **ប.ស.ស.**។

ប្រការ៤ .-

ប.ស.ស. ត្រូវផ្តល់ជូននិយោជកនូវ "**វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីក្នុងបេឡាជាតិសន្តិសុខសង្គម**" បន្ទាប់ពីបានទទួល និងត្រួតពិនិត្យត្រឹមត្រូវនូវសំណើចុះបញ្ជី។

ប្រការ៥ .-

និយោជកត្រូវជូនដំណឹងមក **ប.ស.ស.** ក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ មុនកាលបរិច្ឆេទនៃការបិទ ការព្យួរកិច្ចសន្យាការងារ ការបើកដំណើរការឡើងវិញ ការផ្លាស់ប្តូរទីតាំងសហគ្រាស ឬការកែប្រែស្ថានភាពគតិយុត្តនៃនិយោជក ដោយត្រូវបំពេញតាមទម្រង់ដែលកំណត់ដោយអគ្គនាយក **ប.ស.ស.**។

ប្រការ៦ .-

ក្នុងរយៈពេល ៣(បី)ថ្ងៃយ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទចូលបម្រើការងាររបស់កម្មករនិយោជិត និយោជកត្រូវ៖

- ចុះបញ្ជីកម្មករនិយោជិតដែលមិនទាន់មានបណ្ណសមាជិក **ប.ស.ស.** ជាមួយ **ប.ស.ស.**
- ជូនដំណឹងអំពីកម្មករនិយោជិតដែលមានបណ្ណសមាជិក **ប.ស.ស.** រួចហើយមក **ប.ស.ស.** តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន **ប.ស.ស.** តាមរយៈគេហទំព័រ https://enterprise.nssf.gov.kh ឬតាមរយៈកម្មវិធីទូរសព្ទដៃ NSSF Enterprise App។

ក្នុងករណីមិនអនុវត្តកាតព្វកិច្ចខាងលើ និយោជកត្រូវទទួលបន្ទុកលើថ្លៃចំណាយសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រទាំងស្រុង និងវិភាជន៍បូជាសពចំពោះហានិភ័យការងារដែលកើតលើកម្មករនិយោជិតរបស់ខ្លួន។

ប្រការ៧ .-

ការចុះបញ្ជីកម្មករនិយោជិតនៅស្នាក់ការ **ប.ស.ស.** ដោយផ្ទាល់ ត្រូវធ្វើតាមទម្រង់ "**សលាកបត្រព័ត៌មានសមាជិក ប.ស.ស.**" (ហៅកាត់ថា **ទម្រង់ ១.០២**) ដែលមានចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ឬតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន **ប.ស.ស.**។

ឯកសារភ្ជាប់សម្រាប់ការចុះបញ្ជីមានដូចខាងក្រោម៖

ក- ចំពោះកម្មករនិយោជិតសញ្ជាតិខ្មែរ៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព និង
- សៀវភៅការងារកម្មករនិយោជិតខ្មែរ ឬវិញ្ញាបនបត្រមុខរបរដែលចេញដោយនិយោជក។

ខ- ចំពោះកម្មករនិយោជិតជាជនបរទេស៖

- លិខិតឆ្លងដែនដែលមានសុពលភាព និង
- បណ្ណការងារនិងសៀវភៅការងារជនបរទេស។

ប្រការ៨ .-

ប.ស.ស. ត្រូវផ្តល់ "**បណ្ណសមាជិក ប.ស.ស.**" សម្រាប់បញ្ជាក់ពីអត្តសញ្ញាណសមាជិក ដែលមានលេខអត្តសញ្ញាណសមាជិកជូនដល់កម្មករនិយោជិតដោយឥតគិតថ្លៃ។

ក្នុងករណីបណ្ណសមាជិក **ប.ស.ស.** ខូច ឬបាត់ សមាជិក **ប.ស.ស.** អាចស្នើសុំបណ្ណសមាជិកទុតិយតាតាមទម្រង់ដែលបានកំណត់ដោយ **ប.ស.ស.** ដោយសាមីជនត្រូវបង់ប្រាក់ចំនួន ៥ ០០០(ប្រាំពាន់)រៀល ជូន **ប.ស.ស.**។

គ្រប់សមាជិក **ប.ស.ស.** ដែលបានដាក់ពាក្យស្នើសុំបើកប្រាក់សោធន ត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់ខ្លួន និងទទួលបានបណ្ណសមាជិក **ប.ស.ស.** ថ្មី ដោយឥតគិតថ្លៃ។

ប្រការ៩ .-

និយោជកត្រូវធ្វើរបាយការណ៍អំពីកម្មករនិយោជិតប្រចាំខែមក **ប.ស.ស.** យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ តាមទម្រង់ "**របាយការណ៍កម្មករនិយោជិត**" (ហៅកាត់ថា **ទម្រង់ ១.០៣**) ដែលមានកំណត់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ ដោយត្រូវភ្ជាប់មកជាមួយនូវបញ្ជីបើកប្រាក់ឈ្នួលប្រចាំខែ។

របាយការណ៍អំពីកម្មករនិយោជិតប្រចាំខែត្រូវរៀបចំតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន **ប.ស.ស.** តាមរយៈគេហទំព័រ https://enterprise.nssf.gov.kh ឬតាមរយៈកម្មវិធីទូរសព្ទដៃ NSSF Enterprise App ឬមកស្នាក់ការកណ្តាល **ប.ស.ស.** ឬសាខា **ប.ស.ស.** ខេត្ត ខណ្ឌ ដោយផ្ទាល់។

ក្នុងករណីព្យួរកិច្ចសន្យាការងារ និយោជកត្រូវផ្តល់បញ្ជីកម្មករនិយោជិតដែលត្រូវបានព្យួរកិច្ចសន្យាការងារបន្ទាប់ពីបានបញ្ចូលព័ត៌មានក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមពាក់ព័ន្ធវិស័យការងារ (Labour Centralised Management System – LACMS)។

ប្រការ១០ .-

និយោជកត្រូវប្រមូលភាគទានដែលជាចំណែករបស់ខ្លួន និងជាចំណែករបស់កម្មករនិយោជិត ដើម្បីបង់ភាគទានក្នុងគណនី **ប.ស.ស.** នៅតាមធនាគារដែលបានកំណត់ដោយ **ប.ស.ស.** យ៉ាងយូរបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ តាមរបៀបដូចខាងក្រោម៖

ក- **ចំពោះការបង់ភាគទានប្រចាំខែ** និយោជកត្រូវផ្អែកលើរបាយការណ៍អំពីកម្មករនិយោជិតប្រចាំខែ ដូចមានចែងនៅក្នុងប្រការ៩ នៃប្រកាសនេះ។

ខ- **ចំពោះការបង់ភាគទានប្រចាំឆ្នាំ** និយោជកដែលមានលទ្ធភាពបង់ភាគទានប្រចាំឆ្នាំ អាចស្នើសុំមក **ប.ស.ស.** ដើម្បីបង់ភាគទានប្រចាំឆ្នាំ ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ផ្អែកលើរបាយការណ៍អំពីកម្មករនិយោជិតប្រចាំខែចុងក្រោយ
- ការបង់ភាគទានប្រចាំឆ្នាំត្រូវបង់តាមឆ្នាំនៃប្រតិទិន
- ការបង់ភាគទានប្រចាំឆ្នាំ ត្រូវធ្វើឡើងនៅខែបន្ទាប់ និងគិតចាប់ពីកាលបរិច្ឆេទនៃខែដែលបានស្នើសុំបង់ភាគទាន
- ក្នុងករណីមានការប្រែប្រួលស្ថានភាពកម្មករនិយោជិតនៅក្នុងខែណាមួយ ត្រូវជូនដំណឹងមក **ប.ស.ស.**
- **ប.ស.ស.** នឹងធ្វើការកែតម្រូវការទូទាត់ភាគទានដែលបង់លើស ឬខ្វះតាមចំនួនជាក់ស្តែងនៅដើមឆ្នាំបន្ទាប់។

ការបង់ភាគទានប្រចាំខែ ឬប្រចាំឆ្នាំ ត្រូវគិតជាប្រាក់រៀលតាមអត្រាប្តូរប្រាក់មធ្យមប្រចាំខែអនុវត្តដែលជូនដំណឹងដោយ **ប.ស.ស.** ផ្អែកលើអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។

ប្រការ១១ .-

និយោជកត្រូវបង់ភាគទានតាមគណនីរបស់ **ប.ស.ស.** នៃធនាគារដែល **ប.ស.ស.** បានកំណត់ដោយអនុវត្តតាមរបៀបណាមួយដូចខាងក្រោម៖

- ប្រើប្រាស់ថ្នាលបច្ចេកវិទ្យាព័ត៌មាន **ប.ស.ស.** តាមការគណនាភាគទាន និងចេញ "**លិខិតស្នើសុំបង់និងប្រកាសភាគទានប្រចាំខែ**" ដោយស្វ័យប្រវត្តិ ដើម្បីអាចធ្វើការបង់ភាគទាននៅធនាគារដៃគូ **ប.ស.ស.** និងទទួលបាន "**បង្កាន់ដៃបញ្ជាក់ការបង់ភាគទាន**" ពី **ប.ស.ស.**

- ស្នើសុំផ្ទាល់នៅស្នាក់ការ **ប.ស.ស.** ដោយមន្ត្រីទទួលបន្ទុកត្រូវចេញ "**លិខិតស្នើសុំបង់និងប្រកាសភាគទានប្រចាំខែ**" ដើម្បីយកទៅបង់ភាគទាននៅធនាគារដៃគូ **ប.ស.ស.**។

ប្រការ១២ .-

និយោជក និងកម្មករនិយោជិត ត្រូវមានកាតព្វកិច្ចអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនក្នុងពេលដំណាលគ្នា លើកលែងតែមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

ប្រការ១៣ .-

និយោជកមិនមានកាតព្វកិច្ចបង់ភាគទានចំពោះផ្នែកប្រាក់សោធនតាមរបបភាគទានជាកាតព្វកិច្ចទៀតទេ ចំពោះសមាជិក **ប.ស.ស.** ដែលមានអាយុចាប់ពី ៦០(ហុកសិប)ឆ្នាំឡើង។

ប្រការ១៤ .-

ប្រាក់ឈ្នួលជាប់ភាគទានដែលត្រូវយកមកគណនាសម្រាប់របបសន្តិសុខសង្គមផ្នែកនីមួយៗ ត្រូវអនុវត្តស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ប្រការ១៥ .-

សមាជិក **ប.ស.ស.** ដែលមានបំណងចុះបញ្ជីនិងបង់ភាគទានសម្រាប់របបសន្តិសុខសង្គមផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្ត ត្រូវអនុវត្តតាមទម្រង់ដែលកំណត់ដោយអគ្គនាយក **ប.ស.ស.**។

ប្រការ១៦ .-

សហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលកំពុងដំណើរការ និងមិនទាន់បានចុះបញ្ជីនៅ **ប.ស.ស.** ត្រូវចុះបញ្ជីក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ។

ប្រការ១៧ .-

ប្រកាសលេខ១៦៨/២២ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត និងការបង់ភាគទាន សម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងបេឡាជាតិសន្តិសុខសង្គម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ១៨ .-

អគ្គលេខាធិការ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម អគ្គនាយកនៃអគ្គនាយកដ្ឋានអធិការកិច្ចការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានទំនាក់ទំនងវិជ្ជាជីវៈនិងដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣កើត ខែអាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែកក្កដា ឆ្នាំ២០២៦

រដ្ឋមន្ត្រី

ហោ សួរ

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ:២៧៤/២៥ ក.ស/ប្រ.ត ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ២០២៦ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ កម្មករនិយោជិត និងការបង់ភាគទានក្នុងបេឡាជាតិសន្តិសុខសង្គម

ទម្រង់ ១.០១

ចុះបញ្ជីសហគ្រាស

សម្រាប់មន្ត្រី ប.ស.ស.	
លេខអត្តសញ្ញាណសហគ្រាស	☐☐☐☐☐☐☐☐
ហត្ថលេខា:.....	/ /

១. ឈ្មោះសហគ្រាស.....

ឈ្មោះជាអក្សរឡាតាំង:.....

២. អាសយដ្ឋានទីស្នាក់ការកណ្តាល: អគារ/ផ្ទះលេខ.....ផ្លូវលេខ.....ក្រុម.....ភូមិ.....

ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....ខេត្ត/រាជធានី.....

លេខទូរសព្ទ: ☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:.....

៣. ប្រសិនបើអាសយដ្ឋានកន្លែងធ្វើការដូចគ្នាជាមួយនឹងអាសយដ្ឋានទីស្នាក់ការកណ្តាល ចំណុចលេខ ៣ នេះពុំចាំបាច់ត្រូវបំពេញទេ ☐ ដូចគ្នា

អាសយដ្ឋាននៃកន្លែងធ្វើការងារ: អគារ/ផ្ទះលេខ.....ផ្លូវលេខ.....ក្រុម.....ភូមិ.....

ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....ខេត្ត/រាជធានី.....

លេខទូរសព្ទ: ☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:.....

៤. លេខបញ្ជីពាណិជ្ជកម្ម: ☐☐☐☐☐☐☐☐☐☐☐☐☐ ប្រភេទសហគ្រាស: ☐☐☐☐☐ **(សម្រាប់មន្ត្រី ប.ស.ស.)**

កាលបរិច្ឆេទបើកសហគ្រាស...../...../..... ចំនួនកម្មកររនិយោជិតចុះបញ្ជីដំបូង:.....នាក់/ស្រី.....នាក់

៥. ឈ្មោះនិយោជក ឬម្ចាស់សហគ្រាស:.....ភេទ:.....សញ្ជាតិ:.....

ឈ្មោះជាអក្សរឡាតាំង:.....

អត្តសញ្ញាណបណ្ណលេខ ឬលិខិតឆ្លងដែនលេខ:.....អាសយដ្ឋានអចិន្ត្រៃយ៍: អគារ/ផ្ទះលេខ.....ផ្លូវលេខ.....

ក្រុម.....ភូមិ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....ខេត្ត/រាជធានី.....

លេខទូរសព្ទ: ☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:.....

៦. ឈ្មោះអ្នកតំណាងនិយោជក:.....ភេទ:.....សញ្ជាតិ:.....

ឈ្មោះជាអក្សរឡាតាំង:.....

អត្តសញ្ញាណបណ្ណលេខ ឬលិខិតឆ្លងដែនលេខ:.....អាសយដ្ឋានអចិន្ត្រៃយ៍: អគារ/ផ្ទះលេខ.....ផ្លូវលេខ.....

ក្រុម.....ភូមិ.....ឃុំ/សង្កាត់.....ក្រុង/ស្រុក/ខណ្ឌ.....ខេត្ត/រាជធានី.....

លេខទូរសព្ទ: ☐☐☐☐☐☐☐☐☐ សារអេឡិចត្រូនិក:.....

ខ្ញុំសូមសន្យាថា រាល់ព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន។

..... ថ្ងៃទី.....ខែ.....ឆ្នាំ.....

ហត្ថលេខា និងត្រានិយោជក

ឯកសារថតចម្លងភ្ជាប់មកជាមួយ:
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- បណ្ណប៉ាតង់
- លិខិតដែលមានតម្លៃស្មើ
- អត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែនរបស់និយោជក និងអ្នកតំណាងនិយោជក
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅរបស់និយោជក

ឧបសម្ព័ន្ធទី២ នៃប្រកាសលេខ:២៧៤/ប្រ.ស/ប្រក ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ២០២៦ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ កម្មករនិយោជិត និងការបង់ភាគទានក្នុងបេឡាជាតិសន្តិសុខសង្គម

ទម្រង់ ១.០២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សណាកប័ត្រព័ត៌មានសមាជិក ប.ស.ស.

លេខ៖ .....

លេខអត្តសញ្ញាណសមាជិក ប.ស.ស. ☐☐☐☐☐☐☐ - ☐☐☐☐☐☐☐ - ☐

ក- ព័ត៌មានផ្ទាល់ខ្លួន

១- នាមត្រកូល និងនាមខ្លួន..... ជាអក្សរឡាតាំង.....កេទ.....
សញ្ជាតិ..... ថ្ងៃខែឆ្នាំកំណើត ...../...../..... អត្តសញ្ញាណបណ្ណលេខឬលិខិតឆ្លងដែនលេខ.....

២- ទីកន្លែងកំណើត ផ្ទះលេខ..... ផ្លូវ..... ភូមិ/ក្រុម..... ឃុំ/សង្កាត់.....
ស្រុក/ខណ្ឌ/ក្រុង..... ខេត្ត/រាជធានី.....

៣- អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ..... ផ្លូវ..... ភូមិ/ក្រុម..... ឃុំ/សង្កាត់.....
ស្រុក/ខណ្ឌ/ក្រុង..... ខេត្ត/រាជធានី..... លេខទូរសព្ទ:.....

ខ- ព័ត៌មានការងារ

៤- ឈ្មោះសហគ្រាស..... លេខអត្ត.សហគ្រាស: ☐☐☐☐☐☐☐☐

៥- មុខងារឬតួនាទី.....
កម្រិតចំណេះដឹងទូទៅ..... ប្រាក់ឈ្នួលគោល..... កាលបរិច្ឆេទចូលធ្វើការ...../...../.....

គ- ព័ត៌មានគ្រួសារ

៦- ស្ថានភាពអាពាហ៍ពិពាហ៍ ☐ នៅលីវ ☐ រៀបអាពាហ៍ពិពាហ៍ ☐ មេម៉ាយ/ពោះម៉ាយ

៧- នាមត្រកូល-នាមខ្លួន(ប្តីឬប្រពន្ធ)..... សញ្ជាតិ..... ថ្ងៃខែឆ្នាំកំណើត...../...../.....
អត្តសញ្ញាណបណ្ណលេខ..... លេខទូរសព្ទ.....មុខរបរសព្វថ្ងៃ.....

៨- អំពីកូន.....នាក់

១. នាមត្រកូល-នាមខ្លួន ..... កេទ..... កើតនៅថ្ងៃទី.....ខែ ..... ឆ្នាំ..... មុខរបរ .....
២. នាមត្រកូល-នាមខ្លួន ..... កេទ..... កើតនៅថ្ងៃទី.....ខែ ..... ឆ្នាំ..... មុខរបរ .....
៣. នាមត្រកូល-នាមខ្លួន ..... កេទ..... កើតនៅថ្ងៃទី.....ខែ ..... ឆ្នាំ..... មុខរបរ .....
៤. នាមត្រកូល-នាមខ្លួន ..... កេទ..... កើតនៅថ្ងៃទី.....ខែ ..... ឆ្នាំ..... មុខរបរ .....

៩- ករណីមានអាសន្ន សូមទាក់ទងឈ្មោះ..... លេខទូរសព្ទ.....។

ខ្ញុំបាទ/នាងខ្ញុំ សូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះពិតជាត្រឹមត្រូវប្រាកដមែន។

ធ្វើនៅ.....ថ្ងៃទី.....ខែ.....ឆ្នាំ២០...
ស្នាមមេដៃស្តាំសាមីខ្លួន

ធ្វើនៅ.....ថ្ងៃទី.....ខែ.....ឆ្នាំ២០...
ហត្ថលេខា និងឈ្មោះមន្ត្រីពិនិត្យ

ឯកសារថតចម្លងភ្ជាប់ជាមួយ:
- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- លិខិតឆ្លងដែន(សម្រាប់ជនបរទេស)
- សៀវភៅការងារកម្មករនិយោជិតខ្មែរ ឬលិខិតបញ្ជាក់អំពីមុខរបរនិងការងារពីនិយោជក ឬបណ្ណការងារជនបរទេស

ឧបសម្ព័ន្ធទី៣ នៃប្រកាសលេខ:២៧៤/ប្រ.ស/ប.ក ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ២០២៦ ស្តីពីបែបបទ និងនីតិវិធីនៃ
ការចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ កម្មករនិយោជិត និងការបង់ភាគទានក្នុងបេឡាជាតិសន្តិសុខសង្គម

ទម្រង់ ១.០៣

រចនាសម្ព័ន្ធកម្មករនិយោជិត

១. ឈ្មោះសហគ្រាស:..... ២. លេខអត្តសញ្ញាណសហគ្រាស: | | | | | | | | |

៣. ឈ្មោះសហគ្រាសជាអក្សរឡាតាំង:.....

ល.រ.	អត្តលេខសម្គាល់ខ្លួននៅសហគ្រាស	លេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (សម្រាប់ជនបរទេស)	លេខអត្តសញ្ញាណសមាជិក ប.ស.ស.	លេខសៀវភៅការងារខ្មែរ ឬជនបរទេស	នាមត្រកូល-នាមខ្លួន (ខ្មែរ)	នាមត្រកូល-នាមខ្លួន (ឡាតាំង)	សញ្ជាតិ	ភេទ	ថ្ងៃខែឆ្នាំកំណើត	ថ្ងៃខែឆ្នាំចូលធ្វើការ	ប្រាក់ឈ្នួលគោល (រៀល)	ប្រាក់ឈ្នួលសរុប (រៀល)	កំពុងធ្វើការនៅទីស្នាក់ការកណ្តាលសហគ្រាស ឬសាខា	មុខងារ ឬតួនាទី	ស្ថានភាព

ខ្ញុំសូមប្រកាសថារាល់ព័ត៌មានដែលផ្តល់ជូនខាងលើ ពិតជាត្រឹមត្រូវប្រាកដមែន។

..... ថ្ងៃទី.....ខែ.....ឆ្នាំ.....

ហត្ថលេខា និងត្រានិយោជក